កម្ពុជាថ្មី ប្រចាំថ្ងៃ
KAMPUCHEA THMEY DAILY



សន្តិសុខសង្គម

# រដ្ឋបាលខេត្តព្រះសីហនុ ចុះផ្អាកដំណើរការផលិតកម្មរោងចក្រកែច្នៃស្បែកសត្វមួយកន្លែងដែលធ្វើឲ្យប៉ះពាល់ដល់បរិស្ថានក្នុងតំបន់

បានផុស ២១ ម៉ោង មុន នៅ ថ្ងៃពុធ ២២ តុលា ២០២៥
ដោយ **Sokhom Khon**

រដ្ឋបាលខេត្តព្រះសីហនុ នៅព្រឹកថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៥ បានចុះផ្អាកដំណើរការផលិតកម្មរោងចក្រកែច្នៃស្បែកសត្វមួយកន្លែងរបស់ក្រុមហ៊ុន គូប៊ុន (ខេមបូឌា) KUBON (CAMBODIA) BIOTECHNOLOGY CO., LTD. ក្នុងឃុំសាមគ្គី ស្រុកព្រៃនប់ ក្រោយពីរដ្ឋខេត្តណែនាំជាច្រើនលើកច្រើនសារតែមិនស្តាប់។










សូមចុច Subscribe Channel Telegram កម្ពុជាថ្មី ដើម្បីទទួលបានព័ត៌មានថ្មីៗទាន់ចិត្ត

ការចុះផ្អាកដំណើរការផលិតកម្មរោងចក្រកែច្នៃស្បែកសត្វនេះ គឺអនុវត្តតាមលិខិតលេខ ៤៨២២/០៦២៥ ប.ស្ក/អគព ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៥ របស់ក្រសួងបរិស្ថាន និងលិខិតលេខ ៤៤៧/២៥ សជណ ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០២៥ របស់រដ្ឋបាលខេត្តព្រះសីហនុ។



លោក ឡុង ឌីម៉ង់ អភិបាលរងនៃគណៈអភិបាលខេត្តព្រះសីហនុ បានបញ្ជាក់ថា ក្រុមហ៊ុន គូប៊ុន (ខេមបូឌា) ជាក្រុមហ៊ុនកែច្នៃស្បែកសត្វ នៅក្នុងស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលរោងចក្ររបស់ក្រុមហ៊ុននេះបានបំពុលបរិស្ថាន ធ្វើឱ្យប៉ះពាល់ដល់ជីវចម្រុះជុំវិញតំបន់។



លោកអភិបាលរងបន្ថែមថា កន្លងមកក្រសួងបរិស្ថាន និងរដ្ឋបាលខេត្តធ្លាប់បានធ្វើការណែនាំឱ្យកែតម្រូវ និងធ្វើការផាកពិន័យជាច្រើនលើកច្រើនសារមកហើយ តែក្រុមហ៊ុននៅមិនមានការកែតម្រូវ។ ដូច្នេះ ការផ្អាកដំណើរការផលិតកម្មរោងចក្រនេះ គឺដើម្បីបញ្ឈប់នូវរាល់សកម្មភាពដែលអាចឈានទៅដល់ការបំពុលបរិស្ថានបន្ថែមទៀត ហើយសង្វាក់ផលិតកម្មទាំងមូលនឹងត្រូវផ្អាករហូតដល់មានការកែតម្រូវឱ្យស្របតាមស្តង់ដារបច្ចេកទេស។



បើតាមលោក ឡុង ឌីម៉ង់ ក្នុងបេសកកម្មនេះ តំណាងក្រុមហ៊ុនបានចូលរួមអនុវត្តតាមសេចក្តីជូនដំណឹងរបស់រដ្ឋបាលខេត្ត ដើម្បីរៀបចំស្ថារប្រព័ន្ធលូ និងអាងប្រព្រឹត្តកម្មឱ្យស្របទៅតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួងបរិស្ថាន មុននឹងស្នើសុំបើកដំណើរផលិតកម្មឡើងវិញ៕



**RELATED TOPICS:** #ខេត្តព្រះសីហនុ #ការបំពុលបរិស្ថាន

## YOU MAY LIKE



តំបន់សេដ្ឋកិច្ចពិសេសទាំង ៥ នៅ ខេត្តព្រះសីហនុ មានជាង ២០០ រោងចក្រ ក្រោមទុនវិនិយោគ ប្រមាណ ២ ពាន់លានដុល្លារ



ស្ថានីយប្រព្រឹត្តកម្មទឹកកខ្វក់ ៤ កន្លែង ខេត្តព្រះសីហនុ មានលទ្ធភាពចម្រោះទឹកកខ្វក់បាន ៦២ ៤០០ ម៉ែត្រគូប ក្នុង ១ថ្ងៃ



ការស្រាវជ្រាវ៖ អាហារសមុទ្រពីរប្រភេទ ផ្ទុកជាតិពុលខ្ពស់ និងមីក្រូប្លាស្ទិក ប៉ះធ្ងន់ដល់សុខភាព




សមត្ថកិច្ចខេត្តព្រះសីហនុ ចាប់បានជនសង្ស័យ៣នាក់ ករណីជំរិតទារប្រាក់ជាង១ម៉ឺនដុល្លារពីជនជាតិប៉ាគីស្ថានម្នាក់



ចំណូលមធ្យមពលរដ្ឋខេត្តព្រះសីហនុកើនដល់ ៥ ៥៧៩,៣ ដុល្លារអាមេរិកនៅឆ្នាំ ២០២៤



រោងចក្រធំៗជាង ២០០ ជាមួយទុនជាង ២ ៩៦៤ លានដុល្លារអាមេរិក កំពុងដំណើរការនៅខេត្តព្រះសីហនុ

## ព័ត៌មានពេញនិយម



ព័ត៌មានជាតិ / ៥ ថ្ងៃ ago

១០ចំណុចសំខាន់ៗនៃកិច្ចព្រមព្រៀងសន្តិភាពកម្ពុជា-ថៃ



ព័ត៌មានអន្តរជាតិ / ២ ថ្ងៃ ago

ពូទីន ក៏កំពុងពិចារណា មកចូលរួមកិច្ចប្រជុំអាស៊ាន នៅម៉ាឡេស៊ី ដែរ



ព័ត៌មានអន្តរជាតិ / ២ ថ្ងៃ ago

អ្នកនាំពាក្យកងទ័ពថៃ ដោះសារទាំងមិនចេះខ្មាសថា ថៃអត់ដែលប្រើអាវុធគីមីលើកម្ពុជាទេ



ព័ត៌មានអន្តរជាតិ / ៦ ថ្ងៃ ago

ថៃ បញ្ជូនរថយន្តផ្ទុកមេក្រូ មកចាក់តម្លង់ពីលរដ្ឋខ្មែរនៅភូមិ ព្រៃចាន់







KPT+ កីឡា វប្បធម៌ ជំនឿ ជីវិតកម្សាន្ត នយោបាយ បច្ចេកវិទ្យា ព័ត៌មានជាតិ ព័ត៌មានអន្តរជាតិ សុខភាព សេចក្ដីជូនដំណឹង សេដ្ឋកិច្ច អត្ថាធិប្បាយ ចរាចរ
ទាក់ទងយើងតាមរយៈ អំពីយើង

Copyright © 2021 រក្សាសិទ្ធិដោយកម្ពុជាថ្មី